**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៧ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងផ្លាស់ប្តូរមុខតំណែង នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** តែងតាំងផ្លាស់ប្តូរមុខតំណែង ជា នាយការិយាល័យ និង ជំនួយការ រដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា ប្រចាំនៅបណ្តាប្រទេស ដែលមានរាយនាមដូចខាងក្រោមៈ

១-វរសេនីយ៍ទោ **ឡុង សំរេច** អត្តលេខ ០២៤៩៣៩ ជា នាយការិយាល័យអនុព័ន្ធយោធា និងជាទីប្រឹក្សាយោធា អមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងយ៉ង់ហ្គូន សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ជំនួស ឧត្តមសេនីយ៍ត្រី **កែវ ជ័យសុធារិទ្ធ** ដែលត្រូវចប់អាណត្តិ

២-វរសេនីយ៍ទោ **ជឹន ចិចិត្រ** អត្តលេខ ០៨៤២៣៤ ជា នាយការិយាល័យអនុព័ន្ធយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូនេស៊ី ជំនួស ឧត្តមសេនីយ៍ត្រី **ចាន់រឿន អន្តារ៉ា** ដែលត្រូវចប់អាណត្តិ

៣-វរសេនីយ៍ទោ **ជួន ចិត្យាខន្យា** អត្តលេខ ០៤០៦៧២ ជា ជំនួយការ រដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធាអមស្ថានទូត ព្រះរាជាណាចក្រ កម្ពុជា ប្រចាំទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូនេស៊ី ជំនួស អនុសេនីយ៍ឯក **ហ៊ាន ភិត្យា** ដែលត្រូវចប់អាណត្តិ

៤-វរសេនីយ៍ទោ **ឡុង លីម** អត្តលេខ ២០៦៥៣៥ ជា ជំនួយការ រដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជំនួស វរសេនីយ៍ត្រី **ខឹម សុម៉ាឡែន** ដែលត្រូវចប់អាណត្តិ

៥-វរសេនីយ៍ទោ **ប៉ែន ណារ៉ុខ** អត្តលេខ ០១១៤៧០ ជា ជំនួយការ រដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានទូត ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ជំនួស វរសេនីយ៍ទោ **កៅ គឹមឌន** ដែលត្រូវចប់អាណត្តិ

៦-អនុសេនីយ៍ឯក **ឌី រ៉ាឌុត** អត្តលេខ ១៩៩៧៦៤ ជា ជំនួយការរដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធាអមស្ថានទូតព្រះរាជា ណាចក្រកម្ពុជា ប្រចាំទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ជំនួស អនុសេនីយ៍ឯក **ឈិន ឌុន** ដែលត្រូវចប់អាណត្តិ

៧-អនុសេនីយ៍ទោ **លី ម៉ូលីន** អត្តលេខ ២៣៩៣៨០ ជា ជំនួយការរដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានកុងស៊ុល ព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួស វរសេនីយ៍ទោ **រិទ្ធ ចាន់នៃយ៉ា** ដែលត្រូវចប់អាណត្តិ

**ប្រការ២** ៈរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ មាឃ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ